# កិច្ចព្រមព្រៀងគម្រោង

*******

រវាង

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ជាមួយនឹង

សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ

**សង្ខេបគម្រោងកម្មវិធី**

- ឈ្មោះគម្រោង៖

  **១.គ្រួសារចិញ្ចឹម(ផ្ទះជាក្រុមតាមសហគមន៍)**

  **២.គាំទ្រថវិកាសម្រាប់ការសិក្សាកុមារដែលរស់នៅក្នុងគ្រួសារតាមសហគមន៍**

- ឈ្មោះស្ថាប័នអនុវត្តគម្រោង៖ **សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ**
- អាសយដ្ឋានរបស់ស្ថាប័នអនុវត្តគម្រោង៖ ផ្លូវ៧មករា ភូមិខ្លាកូនថ្មី សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

  ទូរស័ព្ទ៖០៥៤ ៦៤៤១ ៤៤៤/ ០៩៧ ៨២៨១១៧៧ អ៊ីម៉ែល៖opdir.lataste@gmail.com

  ប្រអប់សំបុត្រ៖ ០១០៦ សិរីសោភ័ណ

- (សូមគូសសញ្ញា ✓ នៅក្នុងប្រអប់ណាមួយខាងក្រោម)៖

  ☑ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក

  ☐ អង្គការមិនមែនរដ្ឋាភិបាលបរទេស

- ថិរវេលារបស់គម្រោង៖ **០៣ឆ្នាំ**

- ចាប់ផ្តើម៖........២២ មិថុនា ២០២២........
- បញ្ចប់៖........២១ មិថុនា ២០២៥........

- ថវិកាគម្រោងសរុប៖ **១៨៣ ១១០ ដុល្លារអាម៉េរិក**
- អ្នកផ្តល់ថវិកាគាំទ្រគម្រោង៖

| ឈ្មោះស្ថាប័នផ្តល់ថវិកា | ទឹកប្រាក់(ដុល្លារអាម៉េរិក) |
|---|---|
| សមាគមជួយកុមារកម្ពុជាឡាតាស្តិ៍(AEC-Lataste)ប្រទេសបារាំង | ១៨៣ ១១០ |
| | |
| **សរុប** | **១៨៣ ១១០** |

- គណនីប្រើប្រាស់ថវិកាខាងលើនៅក្នុងប្រទេសកម្ពុជា៖ ធនាគារ CANADIA

  ឈ្មោះគណនីADTJK-AEC-L លេខគណនី0120000002033។

- ប្រភពថវិកាដែលបានផ្តល់ខាងលើទាំងនេះត្រូវតែជាថវិកា ជួយដល់ក្រុមគោលដៅមនុស្សធម៌ សុទ្ធសាធគ្មានការពាក់ព័ន្ធទៅនឹងកិច្ចការយោធា នយោបាយ ឬសាសនាឡើយ។

| **ចំនួនបុគ្គលិក** | **ស្រី** | **ប្រុស** | **សរុប** |
|---|---|---|---|
| បុគ្គលិកខ្មែរ | ៤ | ១ | ៥ |
| បុគ្គលិកបរទេស | ១ | ០ | ១ |
| បុគ្គលិកស្ម័គ្រចិត្តបរទេស | ១ | ០ | ១ |
| **ចំនួនបុគ្គលិកសរុប** | **៦** | **១** | **៧** |

## គោលដៅកិច្ចសហប្រតិបត្តិការ

- ផ្តល់ការថែទាំ ការស្នាក់នៅ ការហូបចុក និងផ្តល់ឧត្តមប្រយោជន៍ដល់កុមារកំព្រា និងកុមារងាយរងគ្រោះ
- ផ្តល់ការសិក្សាដល់កុមារកំព្រា កុមារងាយរងគ្រោះ នៅសាលាចំណេះដឹងទូទៅ
- ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋដែលគ្មានលទ្ធភាពបញ្ជូនកូនទៅសិក្សារៀនសូត្រនៅសាលាចំណេះដឹងទូទៅ ដោយផ្តល់ការឧបត្ថម្ភក្នុងមួយខែពី៧២,០០០ដល់៨៤,០០០រៀល
- ផ្តល់អង្ករ និងសម្ភារៈអនាម័យប្រចាំត្រីមាសដល់គ្រួសាររបស់កុមារ។

## ពណ៌នាគម្រោងកម្មវិធី

គម្រោងនេះបង្កើតឡើងបន្ទាប់ពីពិនិត្យឃើញថា កុមារងាយរងគ្រោះ និងកុមាររងគ្រោះមួយចំនួននៅមិនទាន់ទទួលបានការថែទាំបីបាច់ ការស្នាក់នៅ និងទទួលបានការអប់រំដូចកុមារដទៃ។

ទីកន្លែងគម្រោងនេះ អនុវត្តនៅក្នុងខេត្តបន្ទាយមានជ័យ។

ផលប្រយោជន៍ដែលទទួលបានពីគម្រោងនេះរួមមានៈ

**ក- គ្រួសារចិញ្ចឹម(ផ្ទះជាក្រុមតាមសហគមន៍)**

- មានកុមារចំនួន១៦នាក់ស្រី០៨នាក់ទទួលបានការហូបចុកបីពេលក្នុងមួយថ្ងៃនិងស្នាក់នៅផ្ទះជាក្រុម
- កុមារទៅសាលារៀនដើម្បីរួចផុតពីអនក្ខរភាព មានសុខភាពល្អ និងសុវត្ថិភាពក្នុងការរស់នៅ
- ទទួលបានការសិក្សាបំប៉នបន្ថែម និងសម្ភារៈសិក្សាពីសមាគម
- ទទួលបានសម្លៀកបំពាក់ប្រចាំថ្ងៃ និងឯកសណ្ឋានសិស្ស
- អនុញ្ញាតឱ្យកុមារទៅលេងស្រុកកំណើត និងផ្តល់ថវិកាគាំទ្រ
- ដំណើរកំសាន្តនៅរមនីយដ្ឋានក្រៅខេត្តក្នុងមួយឆ្នាំម្តង
- មានការបង្រៀនរបាំប្រពៃណីខ្មែរ និងគំនូរ
- មានសួនបន្លែឱ្យកុមារចូលរួមសកម្មភាពដាំដុះបន្លែធម្មជាតិ។

**ខ- គាំទ្រថវិកាសម្រាប់ការសិក្សាដល់កុមារដែលរស់នៅក្នុងសហគមន៍**

- ចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋដែលគ្មានលទ្ធភាពបញ្ជូនកូនទៅរៀនហើយជួយជម្រុញកូនចូលរៀន
- ផ្តល់ថវិកាគាំទ្រការសិក្សា ក្នុងមួយខែពី៧២,០០០ ដល់ ៨៤,០០០រៀល
- ឧបត្ថម្ភបន្ថែមនូវ អង្ករ៥០គីឡូក្រាម ថ្នាំដុសធ្មេញ សាប៊ូបោកគក់ សាប៊ូដុសខ្លួន និងផ្តល់ការអប់រំវគ្គខ្លីៗដល់គ្រួសារមួយត្រីមាសម្តង ។
- កុមារទទួលបានការប្រឹក្សា និងតាមដានការសិក្សាពីក្រុមការងារសមាគម។

ក្រុមគោលដៅដែលទទួលបានសេវាខាងលើ គឺជាលទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាងសមាគម និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ចំនួនក្រុមគោលដៅទទួលបានផលប្រយោជន៍ពីគម្រោងកម្មវិធី៖

| ល.រ | ក្រុមគោលដៅ | ចំនួន | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ស្រី | ប្រុស | សរុប | |
| ១ | គ្រួសារចិញ្ចឹម(ផ្ទះជាក្រុមតាមសហគមន៍) | ០៨ | ០៨ | ១៦ | |
| ២ | គាំទ្រឱកាសសម្រាប់ការសិក្សាដល់កុមារដែលរស់នៅក្នុងសហគមន៍ | ៣៤ | ២០ | ៥៤ | |
| សរុប | | ៤២ | ២៨ | ៧០ | |

## លក្ខខណ្ឌលម្អិត

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## និង

## សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ

## បានព្រមព្រៀងដូចខាងក្រោមនេះ

## មាត្រា ១

## លក្ខខណ្ឌទូទៅនៃកិច្ចព្រមព្រៀង

១.១ កិច្ចព្រមព្រៀងនេះ គឺធ្វើឡើងក្រោមកិច្ចសហប្រតិបត្តិការរវាង **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និង **សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ** ទាំងការអនុវត្ត និងការវាយតម្លៃលើសកម្មភាពទាំងមូលរបស់គម្រោង ដើម្បីឲ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

១.២ រាល់ការអនុវត្តកម្មវិធី ត្រូវបានពិភាក្សាជាមួយ និងមន្ទីរជំនាញថ្នាក់រាជធានី ខេត្ត ដែលមានការពាក់ព័ន្ធ។

១.៣ រាល់ការសាងសង់សំណង់ណាមួយ ត្រូវធ្វើការពិភាក្សាល្អិតល្អន់ជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ជាមុនសិនទើបអាចដំណើរការបាន។ រាល់គម្រោង និងប្លង់សាងសង់រួមទាំងក្បាច់រចនា ត្រូវធ្វើឡើងស្របតាមបទដ្ឋានជាតិ។

១.៤ កាលបរិច្ឆេទនៃគម្រោងចាប់ផ្តើមនៅថ្ងៃទី........១៧ ធ្នូ ២០២២........
និងបញ្ចប់ទៅវិញថ្ងៃទី........១៧ ធ្នូ ២០២៥........

១.៥ ក្នុងភាពជាដៃគូការងារ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និង **សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ** បានឯកភាពគ្នាថានឹងធ្វើការពិនិត្យឡើងវិញលើគម្រោងនេះយ៉ាងតិច០៣ខែមុនកាលបរិច្ឆេទបញ្ចប់នៃគម្រោង។ ក្រោយពីបានពិនិត្យ និងពិភាក្សាគ្នារួចហើយសេចក្តីសម្រេចរួមគ្នានឹងត្រូវធ្វើឡើងថាតើត្រូវបញ្ចប់គម្រោងតាមពេលកំណត់ឬក៏ស្វែងរកកិច្ចបន្តគម្រោងនេះមួយ រយៈបន្ថែមទៀត។

១.៦ កិច្ចព្រមព្រៀងនេះត្រូវបានប្រើប្រាស់ជាផ្លូវការដោយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន** និង **យុវនីតិសម្បទា** និង**សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ** សម្រាប់ជាមូលដ្ឋាន ក្នុងការធ្វើសហប្រតិបត្តិការ។

១.៧ **សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ**ត្រូវគោរពតាមច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័ត ឲ្យប្រើប្រាស់នៅ**ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥** ។

## មាត្រា ២
## សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ
## បានព្រមព្រៀង៖

២.១ អនុវត្តការងារដើម្បីសម្រេចនូវទិសដៅរបស់គម្រោងដាក់លាក់ដូចខាងក្រោម៖

- ផ្តល់ការថែទាំ ការស្នាក់នៅ ការហូបចុក និងផ្តល់ឧត្តមប្រយោជន៍ដល់កុមារកំព្រា និងកុមារ ងាយរងគ្រោះ
- ផ្តល់ការសិក្សាដល់កុមារកំព្រា កុមារងាយរងគ្រោះ នៅសាលាចំណេះទូទៅ
- ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ម្រជាពលរដ្ឋដែលមិនមានលទ្ធភាពបញ្ជូនកូនទៅសិក្សារៀនសូត្រនៅ សាលាចំណេះទូទៅ ដោយផ្តល់ថវិកាឧបត្ថម្ភក្នុង១ខែពី ៧២,០០០ ទៅ៨៤,០០០រៀល
- ផ្តល់អង្ករនិងសម្ភារៈអនាម័យប្រចាំត្រីមាសដល់គ្រួសាររបស់កុមារ។

២.២ សហការយ៉ាងជិតស្និទ្ធជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ដែលជាដៃគូការងារដើម្បីទទួលបានលទ្ធផលកម្រិតអតិបរមាក្នុងការផ្ទេរ និងពង្រឹងជំនាញបច្ចេកទេស។

២.៣ រាល់ការបោះពុម្ព ឬឯកសារទាំងឡាយណាដែលបានពីសមិទ្ធផលរបស់គម្រោងនេះ ត្រូវដាក់ជូន ក្រសួងផ្តល់យោបល់រួចហើយនឹងត្រូវចាត់ទុកជាសម្បត្តិរួមគ្នារបស់**សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ** និង**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ។

២.៤ ចូលរួមឲ្យបានទៀងទាត់រាល់កិច្ចប្រជុំនីមួយៗតាមការអញ្ជើញរបស់ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ដើម្បីសម្របសម្រួលសកម្មភាពរបស់គម្រោង ដែលកំពុងដំណើរការព្រមទាំង ធ្វើការផ្លាស់ប្តូរព័ត៌មានគ្នា ដើម្បីឈានទៅសម្រេចជោគជ័យ តាមទិសដៅ របស់គម្រោង។

២.៥ ផ្តល់របាយការណ៍ប្រចាំត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(នៅនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក)។
របាយការណ៍ដូចគ្នានេះ ត្រូវចម្លងជូន៖

១.នាយកដ្ឋានសុខុមាលភាពកុមារ

២.នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

៣.មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលសមាគមកំពុងធ្វើសកម្មភាព

៤.ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុង ស្រុក ដែលអង្គការកំពុងធ្វើសកម្មភាព

២.៦ ក្នុងរយៈពេល១ឆ្នាំ បន្ទាប់ពីក្រសួង និងអង្គការបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាផ្លូវការរួចមកបើ**សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ** ពុំបានផ្ញើរបាយការណ៍ដូចមានចែងនៅក្នុង មាត្រា២.៥ ក្រសួងកំណត់ថា**សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ** ពុំបានអនុវត្តគម្រោងកម្មវិធីហើយត្រូវ ចាត់ទុកជាមោឃៈ និងអស់សុពលភាពដោយស្វ័យប្រវត្តិ។

២.៧ ទទួល ឬបង្គលក្ខណៈដល់មន្ត្រីរបស់ **ក្រសួង និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** រាជធានី ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើការក្នុងគម្រោងកម្មវិធីដោយយោងលើប្រភេទគម្រោងកម្មវិធីដូចជា មធ្យោបាយធ្វើដំណើរកិច្ចសម្របសម្រួលទំនាក់ទំនងការងារ។

២.៨ ជូនដំណឹងមក**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ជាលាយលក្ខណ៍អក្សរនៅពេលដែលអង្គការផ្លាស់ប្តូរអាសយដ្ឋាន ប្រធានអង្គការ គម្រោងកម្មវិធី លេខទូរស័ព្ទ និងទូរសារទំនាក់ទំនង។ ចំពោះករណីមានការនាំចូលឧបករណ៍ និងសម្ភារដែលយកមកប្រើប្រាស់សម្រាប់សកម្មភាពគម្រោង **សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ** ត្រូវជូនដំណឹងមក**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** តាមពេលវេលាសមស្របមុនពេលដែលឧបករណ៍ និងសម្ភារនោះគ្រោងនាំចូលមកដល់ទឹកដីព្រះរាជាណាចក្រកម្ពុជា។

២.៩ គម្រោងថវិកាដែលបានអនុម័តត្រូវប្រើប្រាស់ឲ្យមានប្រសិទ្ធភាពតាមទិសដៅដូចបានកំណត់។

| **គម្រោងចំណាយ** | **២០២២ ២០២៣** | **២០២៣ ២០២៤** | **២០២៤ ២០២៥** | **សរុបទឹកប្រាក់ (គិតជាដុល្លា)** |
|---|---|---|---|---|
| ចំណាយប្រាក់ខែបុគ្គលិកបរទេស | | | | |
| ចំណាយលើប្រាក់ខែបុគ្គលិកខ្មែរ | ១១,២៥៣ | ១២,០៤០ | ១២,៨៨២ | ៣៦,១៧៥ |
| ចំណាយលើប្រាក់ខែបុគ្គលិកតាមសហគមន៍ | | | | |
| ចំណាយសម្រាប់ការិយាល័យ និងការងាររដ្ឋបាលផ្សេងៗ(ថ្លៃទឹកភ្លើង ទូរស័ព្ទនិងអ៊ិនធឺណេត) | ៣,១០៥ | ៣,៣២២ | ៣,៥៥៤ | ៩,៩៨១ |
| **សរុបចំណាយមិនផ្ទាល់** | **១៤,៣៥៨** | **១៥,៣៦២** | **១៦,៤៣៦** | **៤៦,១៥៦** |
| ចំណាយលើការបណ្តុះបណ្តាល | ២៥០ | ២៦៧ | ២៨៥ | ៨០២ |
| ចំណាយលើសិក្ខាសាលា | | | | |
| ចំណាយលើការផ្គត់ផ្គង់សម្ភារបច្ចេកទេស | ៨០០ | ៨៦៣ | ១,០៣០ | ២,៨៩៣ |

| | | | | |
|---|---|---|---|---|
| ចំណាយលើមធ្យោបាយដឹកជញ្ជូន | ១,០០០ | ១,០៧០ | ១,១៤៤ | ៣,២១៤ |
| ចំណាយលើការជួសជុល និងថែទាំ | ២,៤៩០ | ២,៦៦៤ | ២,៨៥០ | ៨,០០៤ |
| ចំណាយលើការសាងសង់ថ្មី | | | | |
| ចំណាយលើជំនួយសង្គ្រោះបន្ទាន់ ឬធានារ៉ាប់រង | ១,៦៨០ | ១,៧៩៧ | ១,២៥៧ | ៤,៧៣៤ |
| ចំណាយលើការទិញរថយន្ត | | | | |
| ចំណាយលើអាហារ៣ពេល/ថ្ងៃ និងសម្លៀកបំពាក់ | ១១,២៥០ | ១២,០៣៧ | ១២,៨៧៩ | ៣៦,១៦៦ |
| ចំណាយលើថ្នាំពេទ្យ ថ្លៃសាលា សម្ភារសិក្សា | ៨០០ | ៨៥៦ | ៩១៥ | ២,៥៧១ |
| គាំទ្រឱកាសសម្រាប់ការសិក្សាដល់កុមារដែលរស់នៅក្នុងសហគមន៍ | ២៤,៤៤០ | ២៦,១៥០ | ២៧,៩៨០ | ៧៨,៥៧០ |
| **សរុបចំណាយផ្ទាល់** | **៤២,៨១០** | **៤៥,៨០៤** | **៤៨,៣៤០** | **១៣៦,៩៥៤** |
| **ថវិកាសរុបរបស់គម្រោង** | **៥៧,១៦៨** | **៦១,១៦៦** | **៦៤,៧៧៦** | **១៨៣,១១០** |

២.១០ ជំនួយរបស់**សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវជនខ្មែរ**ជាជំនួយសម្រាប់មនុស្សធម៌ សុទ្ធសាធ នឹងមិនប្រើប្រាស់ជំនួយនេះ ក្នុងគោលបំណងនយោបាយ សាសនា ឬយោធា ឡើយ។

២.១១ គោរពតាមច្បាប់ អនុក្រឹត្យ ប្រកាស បទដ្ឋាន គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាអាទិ៍៖

- អនុក្រឹត្យលេខ ១១៩ .អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ។
- អនុក្រឹត្យលេខ៣៤ .អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងការប្រគល់មុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ទៅឱ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ។
- ប្រកាសលេខ២១៧ ស.អ.យ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦ ស្តីពីការដាក់អោយអនុវត្ត
- គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ។
- ប្រកាសលេខ ២២៨០ ស.អ.យ ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១១ ស្តីពីនីតិវិធីអនុវត្តគោលនយោបាយ
- ស្តីពីការថែទាំជំនួសចំពោះកុមារ។
- ប្រកាសលេខ៦១៦ ស.អ.យ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល។
- គោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារលេខ៩០៧ ស.អ.យ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៦។

- ប្រកាសលេខ១១៩៨ ស.អ.យ ចុះថ្ងៃទី១១ ខែមិនា ឆ្នាំ២០០៨ស្ដីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមារនៅតាមសហគមន៍។
- ប្រកាសលេខ ១៨០១ ស.អ.យ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ ស្ដីពីការទទួលស្គាល់គុណវុឌ្ឍិនៃអង្គការសុវត្ថិភាពកុមារ។
- ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០១៩-២០២៣។

២.១២ អង្គការត្រូវសហការជាមួយក្រសួងស.អ.យ លើកម្មវិធីបង្រួបបង្រួមគ្រួសារ ដើម្បីបំពេញកិច្ចការឲ្យបានគ្រប់ជ្រុងជ្រោយ និងប្រកបដោយការទទួលខុសត្រូវ ។ អង្គការត្រូវធ្វើការវាយតម្លៃ១ឆ្នាំម្ដងពីលទ្ធភាពធ្វើសមាហរណកម្មឲ្យកុមាររទៅរស់នៅជាមួយគ្រួសារ សាច់ញាតិ ឪពុកម្ដាយធម៌នៅក្នុងសហគមន៍ ។ ក្នុងរយៈពេល២ឆ្នាំដំបូង បុគ្គលិកអង្គការត្រូវចុះតាមដានកុមារដែលបានធ្វើសមាហរណកម្មជារៀងរាល់ត្រីមាស ។ ចាប់ពីឆ្នាំ២០១៨ ការទទួលទុកដាក់កុមារត្រូវបំពេញទម្រង់គ្រប់គ្រងករណីថ្មី និងគំរូលិខិតបទដ្ឋានឲ្យស្របតាមការអនុវត្តប្រកាសស្ដីពីនីតិវិធីអនុវត្តគោលនយោបាយស្ដីពីការថែទាំជំនួសចំពោះកុមារ។

២.១៣ អនុញ្ញាតឲ្យមន្ត្រី **ក្រសួង និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** រាជធានី ខេត្ត ចុះត្រួតពិនិត្យវាយតម្លៃ និងតាមដានគម្រោងកម្មវិធីរបស់អង្គការ។

២.១៤ ផ្ដល់ច្បាប់ថតចម្លងកិច្ចព្រមព្រៀងនេះទៅនាយកដ្ឋានជំនាញ និង**មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** រាជធានី ខេត្ត ដែលអង្គការធ្វើសកម្មភាពក្រោយពីកិច្ចព្រមព្រៀងនេះចូលជាធរមាន។

## មាត្រា ៣
## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមព្រៀង៖

៣.១ ចាត់តាំងបុគ្គលិកដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពសមស្រប (ថ្នាក់ក្រសួង មន្ទីរ ក្រុង ស្រុក ខណ្ឌ) ឲ្យបំពេញការងារជាមួយ **សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវជ័យខ្មែរ** ដើម្បីឲ្យសកម្មភាពគម្រោងអនុវត្តទៅមានប្រសិទ្ធិភាព និងទាន់ពេលវេលា។

៣.២ អនុញ្ញាតឲ្យ**សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវជ័យខ្មែរ** អាចជួលបុគ្គលិកកម្ពុជាធ្វើការបានដោយអនុលោមតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។

៣.៣ សម្របសម្រួលក្នុងករណីចាំបាច់ដល់ការសុំទិដ្ឋាការឲ្យបុគ្គលិក និងទីប្រឹក្សារបស់អង្គការដែលចូលរួមក្នុងសកម្មភាពគម្រោង ដែលត្រូវបានទទួលស្គាល់តាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។

៣.៤ សម្របសម្រួលតាមករណីសមស្របដើម្បីស្នើសុំពន្ធ និងអាករជាបន្ទុករបស់រាជរដ្ឋាភិបាលកម្ពុជាលើឧបករណ៍ និងសម្ភារដែលយកមកប្រើប្រាស់គាំទ្រឲ្យសកម្មភាពគម្រោង។

៣.៥ ជំរុញឲ្យមន្ទីរជំនាញរាជធានី ខេត្ត ឬក្រុង ស្រុក ខណ្ឌ ធ្វើការប្រាស្រ័យទាក់ទងឲ្យបានជិតស្និទ្ធជាមួយអង្គការ ដើម្បីជួយកសាងផែនការគ្រប់គ្រង និងដោះស្រាយបញ្ហា។

៣.៦ រាល់សំណើផ្សេងៗពីអង្គការ នឹងត្រូវបានផ្តល់ចម្លើយពីក្រសួងវិញជាលាយលក្ខណ៍អក្សរ។

៣.៧ អនុញ្ញាត**សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវជនខ្មែរ** ពិភាក្សាជាមួយនាយកដ្ឋានជំនាញ ឬអង្គភាពពាក់ព័ន្ធរបស់ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** លើកិច្ចដំណើរការដើម្បីសម្រេចបាននូវការព្រមព្រៀងផ្សេងៗ ស្របតាមលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង រួចស្នើសុំសេចក្តីសម្រេចពីរដ្ឋមន្ត្រី **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ។

## មាត្រា ៤
## លក្ខខណ្ឌរួម

៤.១ ប្រធាន**សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវជនខ្មែរ** ត្រូវជ្រើសតាំងជាតំណាងស្របច្បាប់ដោយ **សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវជនខ្មែរ** នឹងត្រូវផ្តល់សិទ្ធិជាតំណាង អង្គការនេះដើម្បីធ្វើការជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ។

៤.២ វិសោធនកម្មជាលាយលក្ខណ៍អក្សរនៃកិច្ចព្រមព្រៀងនេះ អាចធ្វើទៅបានដោយមានការព្រមព្រៀងគ្នាទៅវិញទៅមក និងចុះហត្ថលេខាដោយភាគីទាំងពីរបន្ទាប់ពីបានពិចារណារួចហើយ។

៤.៣ កិច្ចព្រមព្រៀងនេះ អាចត្រូវបានបញ្ចប់ក្នុងស្ថានភាពបន្ទាន់តាមការសម្រេចរួមគ្នាមួយរវាងតំណាង **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និង**សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវជនខ្មែរ** ក្រោយពីបានពិគ្រោះ និងពិចារណារួចរាល់ហើយ។

៤.៤ **សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវជនខ្មែរ** មានសិទ្ធិបញ្ឈប់សកម្មភាពភ្លាមលើកិច្ចព្រមព្រៀងនេះក្រោយពីបានពិភាក្សាជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា** ប្រសិនជាពិនិត្យឃើញថា គ្មានកិច្ចសហប្រតិបត្តិការគ្រប់គ្រាន់សម្រាប់ការអនុវត្តគម្រោងឲ្យមានប្រសិទ្ធភាព ឬសន្តិសុខនៃបុគ្គលិក ឬទ្រព្យសម្បត្តិរបស់ខ្លួនស្ថិតក្នុងប្រធានស័ក្ត។

៤.៥ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** មានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះ ដោយចេញលិខិតរបស់ក្រសួងជាផ្លូវការ ប្រសិនបើការអនុវត្តដំណោះស្រាយ ដូចក្នុងមាត្រា ៤.២ ៤.៣ និង៤.៤ នៃកិច្ចព្រមព្រៀងនេះមិនអាចសម្រេចបាន ឬមានគោលការណ៍ថ្មីតម្រូវ ។

៤.៦ បន្ទាប់ពីបានពិភាក្សាជាមួយ **សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវជនខ្មែរ** រួច **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** នឹងស្នើសុំឲ្យសមាគម/អង្គការបញ្ឈប់ការងារចំពោះបុគ្គលិកណាដែលត្រូវបានវិនិច្ឆ័យថា ធ្វើឲ្យខូចកិត្តិយសក្រសួង ឬបានប្រព្រឹត្តខុសនឹង ក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួនហើយ **សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវជនខ្មែរ** ត្រូវតែអនុវត្តតាមដំណើរការនេះ។

៤.៧ ក្រោយពីបានពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** មានសិទ្ធិបញ្ឈប់កិច្ចព្រមព្រៀងនេះ ប្រសិនបើតំណាងផ្លូវការរបស់ **សមាគម**

**អភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ** ត្រូវបានគេវិនិច្ឆ័យឃើញថាមិនបានបំពេញតាម មាត្រា២ នៃកិច្ចព្រមព្រៀងនេះ។

៤.៨ កិច្ចព្រមព្រៀងនេះ អនុញ្ញាតឲ្យអង្គការបន្តកិច្ចសហប្រតិបត្តិការជាមួយ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** ក្នុងបរិវេលាដូចមានចែងក្នុងចំនុច១.៤ ។ ចំពោះការគ្រប់គ្រងកុមារ អង្គការត្រូវអនុវត្តតាមបទដ្ឋាននានាពាក់ព័ន្ធទៅ នឹងកុមារដែលក្រសួងស.អ.យ បានផ្សព្វផ្សាយអនុវត្ត ហើយការទទួលខុសត្រូវ ស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់នាយកដ្ឋានទទួលបន្ទុកវិស័យកុមាររបស់ក្រសួងស.អ.យ បន្តធ្វើសមាហរណកម្មកុមារក្នុងទិសដៅបង្រួបបង្រួមកុមារក្នុងគ្រួសារ ដូចនេះតម្រូវឲ្យអង្គការត្រូវបំពេញបែបបទ និងលក្ខខណ្ឌនានាដែលមានការបញ្ជាក់ពីការគ្រប់គ្រងរបស់នាយកដ្ឋានសុខុមាលភាពកុមារ។

៤.៩ ប្រសិនបើ **សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ** មិនគោរពតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** អាចបញ្ឈប់កិច្ចព្រមព្រៀងនេះ បន្ទាប់ពីជូនព័ត៌មានដល់សាមីអង្គការនោះរួចមក។

៤.១០ កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា ហើយមានសុពលភាពរហូតដល់ថ្ងៃបញ្ចប់គម្រោង។

*កិច្ចព្រមព្រៀងនេះ ត្រូវបានរៀបចំឡើងដោយឥតកែប្រែជាភាសាខ្មែរចំនួនពីរច្បាប់។*

ចុះហត្ថលេខានៅថ្ងៃទី ៣រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២២ ។

**ហត្ថលេខី**

| | |
|---|---|
| **តំណាង៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | **តំណាង ៖ សមាគមអភិវឌ្ឍន៍បច្ចេកទេសយុវវ័យខ្មែរ** |
| ឯ.ឧ **តូច ចាន់នី** | លោក **សួរ ម៉ាខ្សៃ** |
| តួនាទី ៖ **អគ្គនាយកបច្ចេកទេស** | តួនាទី ៖ **នាយកប្រតិបត្តិ** |